ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៣៨.......អយក. សណន

# សេចក្តីណែនាំ
# ស្តីពី
# ការបើកដំណើរការឡើងវិញគ្រឹះស្ថានបឋមសិក្សា
# ក្នុងដំណាក់កាលទី២

ក្រោយពីការដាក់ឱ្យអនុវត្តវិស្សមកាលតូចមុនកាលកំណត់ និងការដាក់ឱ្យបន្តវិស្សមកាល ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ គ្រឹះស្ថានបឋមសិក្សា និងសិស្សានុសិស្សមួយចំនួនបានអនុវត្តការបង្រៀននិងរៀនពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិក និងការសិក្សាពីចម្ងាយតាមបែបប្រពៃណី ក្រោមការជួយគាំទ្ររបស់មាតាបិតា អ្នកអាណាព្យាបាល លោកគ្រូ អ្នកគ្រូ និងគណៈគ្រប់គ្រងសាលារៀន។

ដើម្បីធានាថា ការបើកដំណើរការឡើងវិញគ្រឹះស្ថានសិក្សាបឋមសិក្សា ក្នុងដំណាក់កាលទី២ ប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាព ក្រសួងសូមធ្វើការណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គ្រប់គ្រឹះស្ថានបឋមសិក្សាសាធារណៈ មាតាបិតា អ្នកអាណាព្យាបាល សិស្សានុសិស្ស ព្រមទាំងគណៈកម្មការគ្រប់គ្រងសាលារៀន/គណៈកម្មការទ្រទ្រង់សាលារៀន ស្តីពីការត្រៀមលក្ខណៈនិងការបើកដំណើរការគ្រឹះស្ថានបឋមសិក្សាឡើងវិញ ដូចខាងក្រោម៖

## ១- ការត្រៀមលក្ខណៈដើម្បីបើកដំណើរការគ្រឹះស្ថានបឋមសិក្សាឡើងវិញ

គណៈគ្រប់គ្រងគ្រឹះស្ថានបឋមសិក្សាទាំងអស់ ត្រូវពិនិត្យលក្ខណៈសម្បត្តិរបស់គ្រឹះស្ថានសិក្សាខ្លួនដូចតទៅ៖

- អនុវត្តតាម **"គោលការណ៍ប្រតិបត្តិស្តង់ដា សម្រាប់ដំណើរការសាលារៀនឡើងវិញ ក្នុងបរិបទកូវីដ-១៩ SOP"** ជាពិសេសពង្រឹងការអនុវត្តវិធានការការពារ ទប់ស្កាត់ និងឆ្លើយតបការរីករាលដាលជំងឺកូវីដ-១៩ របស់ក្រសួងសុខាភិបាល ដូចជា៖

**ការរៀបចំបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាព បរិយាបន្ន ផាសុកភាព និងមេត្រីភាព**

  - ត្រូវអនុវត្តវិធានការសម្លាប់មេរោគ មុននឹងដាក់ឱ្យដំណើរការគ្រឹះស្ថានសិក្សា ជាពិសេស បន្ទប់រៀន បណ្ណាល័យ បន្ទប់ពិសោធន៍ អាហារដ្ឋាន បង្គន់អនាម័យ កន្លែងលាងសម្អាតដៃ អគារនានា សួនកំសាន្ត និងសម្ភារប្រើប្រាស់ចាំបាច់ផ្សេងៗ
  - ត្រូវរៀបចំធ្វើអនាម័យបោសសម្អាតបន្ទប់រៀន អគារនានា និងបរិវេណគ្រឹះស្ថានសិក្សា និងត្រូវគ្រប់គ្រងការទុកដាក់សំរាមឱ្យបានត្រឹមត្រូវប្រចាំថ្ងៃ។


អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ការថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរក្សាគម្លាតសុវត្ថិភាពក្នុងគ្រឹះស្ថានសិក្សា

- ត្រូវរៀបចំតុកៅអីអង្គុយសម្រាប់អ្នកសិក្សានៅក្នុងបន្ទប់រៀន ដោយរក្សាគម្លាតសុវត្ថិភាពយ៉ាងតិច ២ម៉ែត្រ និងរៀបចំចំណុះថ្នាក់ ដោយកំណត់សិស្សមិនលើសពី ១៥នាក់ ទៅ ២០នាក់ក្នុង ១ថ្នាក់
- ត្រូវបើកច្រកទ្វារចេញចូលក្នុងបរិវេណគ្រឹះស្ថានបឋមសិក្សាទាំងអស់ ដើម្បីកាត់បន្ថយការប្រមូលផ្តុំ មនុស្សច្រើនកកកុញ ដោយតម្រូវឱ្យឈរតម្រង់ជួរឃ្លាតពីគ្នាចាប់ពី ១,៥ ម៉ែត្រឡើងទៅ នៅច្រកទ្វារចេញចូលគ្រឹះស្ថានសិក្សា
- ត្រូវបែងចែកវេនសិស្សមួយចំនួននៅក្នុងបន្ទប់ និងមួយចំនួនចេញក្រៅបន្ទប់រៀន នៅពេលចេញលេងម្តងៗ ព្រមទាំងត្រូវជានាគម្លាតសុវត្ថិភាពពេលចូលប្រើប្រាស់បង្គន់អនាម័យ ឬកន្លែងលាងសម្អាតដៃ។

ការលើកកម្ពស់សុខភាពចាំបាច់ដល់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកផ្សេងទៀត

- ត្រូវពិនិត្យលទ្ធភាពរៀបចំបន្ទប់សុខភាព និងចាត់តាំងឱ្យមានគ្រូទទួលបន្ទុកសុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សានីមួយៗ សម្រាប់ការសង្គ្រោះបឋម ការពិនិត្យសុខភាពជូនអ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកផ្សេងទៀតដែលបម្រើការនៅក្នុងគ្រឹះស្ថានសិក្សា
- ត្រូវណែនាំមាតាបិតា អ្នកអាណាព្យាបាល ឱ្យផ្តល់ព័ត៌មានអំពីសុខភាព ប្រវត្តិនៃការធ្វើដំណើរក្នុងនិងក្រៅប្រទេស និងការជួបជុំរបស់កូន ដែលអាចបង្កើតហានិភ័យនៃការឆ្លងជំងឺកូវីដ-១៩
- ត្រូវចាត់វិធានការវាស់កម្តៅអ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកផ្សេងទៀតដែលបម្រើការនៅក្នុងគ្រឹះស្ថានសិក្សាជាប្រចាំ មុនពេលចូលក្នុងបរិវេណគ្រឹះស្ថានសិក្សា។ ករណីរកឃើញមានកម្តៅចាប់ពី ៣៧,៥អង្សាសេឡើងទៅ មិនត្រូវអនុញ្ញាតឱ្យចូលក្នុងគ្រឹះស្ថានសិក្សាឡើយ ហើយត្រូវណែនាំ និងអនុញ្ញាតឱ្យសម្រាកនៅផ្ទះ ឬ ទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យ ឬ មណ្ឌលសុខភាព
- ត្រូវរៀបចំវិធានការកុំឱ្យមានការកកស្ទះពេលចូលសាលារៀន និងពេលចេញពីសាលារៀនដោយកំណត់កាលវិភាគច្បាស់លាស់អំពីការមកដល់ និងពេលចេញរបស់បុគ្គលិកអប់រំនិងអ្នកសិក្សា ដើម្បីកុំឱ្យចូលនិងចេញក្នុងពេលតែមួយ ទាំងក្នុងបរិវេណគ្រឹះស្ថានសិក្សានិងពេលចូលក្នុងបន្ទប់រៀន។

ការផ្គត់ផ្គង់ទឹកស្អាត និងបរិក្ខារអនាម័យ

- ត្រូវពិនិត្យលទ្ធភាពផ្គត់ផ្គង់ទឹកស្អាតនៅក្នុងគ្រឹះស្ថានសិក្សា ជូនដល់អ្នកសិក្សា បុគ្គលិកអប់រំ និងលើកទឹកចិត្តឱ្យយកទឹកស្អាតមកពីផ្ទះ សម្រាប់ទុកទទួលទានផ្ទាល់ខ្លួន
- ត្រូវរៀបចំបរិក្ខារលាងសម្អាតដៃឱ្យបានច្រើនកន្លែងនៅជិតបង្គន់អនាម័យ ឬក្បែរបន្ទប់រៀនដោយមានសាប៊ូ និងមានទឹកស្អាតប្រើប្រាស់ជាប្រចាំ សមស្របតាមតម្រូវការរបស់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតក្នុងគ្រឹះស្ថានសិក្សា

- ត្រូវពិនិត្យលទ្ធភាពរកទឹករម្ងាប់មេរោគដូចជា អាល់កុល ឬ ជែលលាងដៃ សម្រាប់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកបម្រើការផ្សេងទៀតក្នុងគ្រឹះស្ថានសិក្សាបានប្រើប្រាស់ប្រចាំថ្ងៃ។

**ការអប់រំសុខភាព និងបណ្តុះបណ្តាលអំពីវិធាននៃការបង្ការជំងឺកូវីដ-១៩**

- ត្រូវណែនាំដល់អ្នកសិក្សា បុគ្គលិកអប់រំ និងបុគ្គលិកផ្សេងទៀតក្នុងគ្រឹះស្ថានសិក្សា ស្តីពីសារៈសំខាន់នៃការរក្សាគម្លាតសុវត្ថិភាព ការបង្ការជំងឺកូវីដ-១៩ និងការរម្ងាប់មេរោគនៅតាមគ្រឹះស្ថានសិក្សា
- ត្រូវធ្វើការហាមឃាត់បុគ្គលិកអប់រំ និងអ្នកសិក្សាមិនឱ្យធ្វើដំណើរទៅកន្លែងដែលអាចមានអត្រាឆ្លងជំងឺកូវីដ-១៩ខ្ពស់ និងមិនត្រូវរៀបចំសកម្មភាពណាដែលអាចបង្កឱ្យមានហានិភ័យនៃការចម្លងរោគ
- ត្រូវណែនាំដល់អ្នកសិក្សា បុគ្គលិកអប់រំ ឬបុគ្គលិកផ្សេងទៀតធ្វើការខ្ទប់មាត់ និងច្រមុះនៅពេលក្អកឬកណ្តាស់ដោយប្រើគន្លាក់កែងដៃឬក្រដាសអនាម័យ រួចបោះចោលក្នុងធុងសំរាមឱ្យបានត្រឹមត្រូវ។

– បង្កើត "**គណៈកម្មការគ្រប់គ្រងសាលារៀន**" ដែលមានសមាសភាពមកពីក្រុមប្រឹក្សាឃុំ សង្កាត់ តំណាងមាតាបិតា និងបុគ្គលិកមណ្ឌលសុខភាព/មន្ទីរពេទ្យបង្អែក ដែលនៅជិតបំផុត។ ចំពោះគ្រឹះស្ថានសិក្សាដែលមានគណៈកម្មការគ្រប់គ្រងសាលារៀនស្រាប់ ប៉ុន្តែមិនមានសមាសភាពដូចបានរៀបរាប់ខាងលើ ត្រូវកែសម្រួលដោយបន្ថែមសមាសភាពដែលមានអ្នកពាក់ព័ន្ធ ហើយគណៈកម្មការនេះ មានតួនាទី ភារកិច្ច បន្ថែមលើតួនាទីភារកិច្ចដែលមានស្រាប់ ដូចតទៅ៖

  - ធ្វើយុទ្ធនាការផ្សព្វផ្សាយស្តីពី ការចូលរៀនឡើងវិញឱ្យបានទូលំទូលាយដល់មាតាបិតា អ្នកអាណាព្យាបាល សិស្សានុសិស្ស និងសហគមន៍
  - ពិនិត្យលទ្ធភាពស្វែងរកសម្ភារៈ ថវិកាដើម្បីជួយដល់សាលារៀន ក្នុងការលើកកម្ពស់ការបង្រៀននិងរៀន សុខភាពនិងអនាម័យសិក្សា និងការកែលម្អបរិស្ថានសាលារៀន
  - ពិនិត្យលទ្ធភាពវិភាជន៍ថវិកាមូលនិធិឃុំ/សង្កាត់ដើម្បីជួយដល់វិស័យអប់រំនៅតាមមូលដ្ឋាន
  - បន្តពិភាក្សា និងសហការជាមួយមាតាបិតា អ្នកអាណាព្យាបាល ដែលមានកូនចៅរៀនជាមួយគ្នា ឬកម្រិតថ្នាក់ដូចគ្នា ដើម្បីបង្កលក្ខណៈឱ្យកូនៗបានរៀនពីចម្ងាយ ឬតាមប្រព័ន្ធអេឡិចត្រូនិក ប្រកបដោយប្រសិទ្ធភាព និងផាសុកភាព
  - ណែនាំមាតាបិតា អ្នកអាណាព្យាបាល ឱ្យយកចិត្តទុកដាក់លើការសិក្សារបស់កូន ជួយបង្រៀនកូនបន្ថែមនៅផ្ទះ ឬបង្កលក្ខណៈងាយស្រួលដល់ការសិក្សារបស់កូន ដោយផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម៖
    - ណែនាំនិងរំឭកអំពីកម្មវិធី ឬ កាលវិភាគ ដែលក្រសួងផ្សាយផ្ទាល់ ឬចាក់ផ្សាយការបង្រៀនទៅតាមមុខវិជ្ជា និងកម្រិតថ្នាក់នីមួយៗ
    - ជួយបង្រៀនកូន ឬ អង្គុយរៀនជាមួយកូន (សម្រាប់កុមារតូចៗ) ពន្យល់កូនបន្ថែម និងចាំជួយលើកទឹកចិត្តកូន

- ផ្តល់ព័ត៌មាន ឬស្នើសុំជំនួយទៅគ្រូបង្រៀន គណៈគ្រប់គ្រងសាលារៀន ឬអាជ្ញាធរដែនដី លើការជំរុញ និងលើកកម្ពស់ការសិក្សារបស់កូន
- អប់រំ និងណែនាំកូនចៅឱ្យថែរក្សាសុខភាព អនាម័យខ្លួនប្រាណ លាងសម្អាតដៃនឹងសាប៊ូឱ្យបានញឹកញាប់ និងត្រឹមត្រូវតាមគោលការណ៍ណែនាំ។

## ២- វិសាលភាពនៃការបើកដំណើរការគ្រឹះស្ថានបឋមសិក្សាឡើងវិញ

- គ្រឹះស្ថានបឋមសិក្សាសាធារណៈ ស្ថិតក្នុងរដ្ឋបាលក្រុងនៃខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី ត្រូវអនុវត្ត **ការរៀនពេញលេញ** និងមានចំណុះថ្នាក់ពី ១៥នាក់ ទៅ ២០នាក់
- គ្រឹះស្ថានបឋមសិក្សាសាធារណៈទាំងអស់ (ក្រៅពីរដ្ឋបាលក្រុងនៃខេត្តទាំង ៤ ខាងលើ) ត្រូវអនុវត្តក្នុង**ទ្រង់ទ្រាយតូច និងការសិក្សាតាមបែបចម្រុះ** ដោយគួបផ្សំការសិក្សាក្នុងថ្នាក់រៀន និងការសិក្សាពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិក និងតាមបែបប្រពៃណី (សន្លឹកកិច្ចការជំនួយ) រួមទាំងការធ្វើស្វ័យ-សិក្សា (សម្រាប់សិស្សនៅទីជនបទ)។

## ៣- ការអនុវត្តកម្មវិធីសិក្សា

គ្រប់គ្រឹះស្ថានបឋមសិក្សាសាធារណៈ ត្រូវបើកដំណើរការសាលារៀនឡើងវិញ(ទាំងការសិក្សាពេញលេញ និងការសិក្សាតាមបែបចម្រុះ) តាមចំណុចទី២ខាងលើ ចាប់ពីថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ តទៅ៖

- នៅថ្ងៃទី០១ ខែកញ្ញា គ្រប់គ្រឹះស្ថានបឋមសិក្សាត្រូវសម្អាតបរិស្ថាននិងរៀបចំស្តង់ដាអនាម័យ ទៅតាមការណែនាំអនុវត្តនៃគោលការណ៍ប្រតិបត្តិស្តង់ដា SOP
- ដំណើរការបង្រៀននិងរៀន ត្រូវអនុវត្តចាប់ពីថ្ងៃទី០៧ ខែកញ្ញា រហូតដល់ដំណាច់ខែធ្នូ
- អនុវត្តការបង្រៀននិងរៀន លើមុខវិជ្ជាសិក្សាគោលពីរគឺ ភាសាខ្មែរ និងគណិតវិទ្យា
- មុខវិជ្ជាផ្សេងទៀតត្រូវព្យួរសិន ដោយនឹងត្រូវរៀនបំពេញបន្ថែម នៅដើមឆ្នាំសិក្សាបន្ទាប់
- ការរៀបចំកម្មវិធីសិក្សាសម្រាប់**ការអនុវត្តពេញលេញ ពីថ្នាក់ទី១ ដល់ទី៦ (ទីរួមខេត្តទាំង ៤)** ៖
    - ក្នុងមួយសប្តាហ៍ សិស្សត្រូវរៀនជាមួយគ្រូផ្ទាល់នៅសាលារៀនចំនួន ៣ថ្ងៃ (រយៈពេល៤ម៉ោងសិក្សា/ថ្ងៃ) ស្មើនឹង ១២ម៉ោងសិក្សា ក្នុងនោះមុខវិជ្ជាភាសាខ្មែរ ៧ម៉ោងសិក្សា និងគណិតវិទ្យា ៥ម៉ោងសិក្សា
    - សម្រាប់ ៣ថ្ងៃ ផ្សេងទៀត សិស្សត្រូវរៀនខ្លួនឯងនៅផ្ទះ ឬតាមបណ្តុំ តាមរយៈការសិក្សាពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិក (ដូចជាប៉ុស្តិ៍ទូរទស្សន៍ ទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា និងតាមបណ្តាញទំនាក់ទំនងសង្គមផ្សេងទៀត) និងការសិក្សាពីចម្ងាយតាមបែបប្រពៃណីតាមរយៈការចែកសន្លឹកកិច្ចការ ឬ មេរៀនសង្ខេបដែលនាយកដ្ឋាន ឬ គ្រូផ្តល់ជូន។
- ការរៀបចំកម្មវិធីសិក្សាសម្រាប់**ការអនុវត្តទ្រង់ទ្រាយតូច ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ (ក្រៅពីរដ្ឋបាលក្រុងនៃខេត្តទាំង ៤ ខាងលើ)**៖
    - ក្នុងមួយសប្តាហ៍ សិស្សត្រូវរៀនជាមួយគ្រូផ្ទាល់នៅសាលារៀនចំនួន ២ថ្ងៃ (រយៈពេល៤ម៉ោងសិក្សា/ថ្ងៃ) ស្មើនឹង ៨ម៉ោងសិក្សា ក្នុងនោះមុខវិជ្ជាភាសាខ្មែរ ៥ម៉ោងសិក្សា និងគណិតវិទ្យា ៣ម៉ោងសិក្សា

  ○ សម្រាប់ ៤ថ្ងៃ ផ្សេងទៀត សិស្សត្រូវរៀនខ្លួនឯងនៅផ្ទះ ឬ តាមបណ្តុំ តាមរយៈការសិក្សាពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិក (ដូចជាប៉ុស្តិ៍ទូរទស្សន៍ ទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា និងតាមបណ្តាញទំនាក់ទំនងសង្គមផ្សេងទៀត) និងការសិក្សាពីចម្ងាយតាមបែបប្រពៃណី តាមរយៈការចែកសន្លឹកកិច្ចការ ឬ មេរៀនសង្ខេបដែលនាយកដ្ឋាន ឬ គ្រូផ្តល់ជូន។

- មុននឹងបញ្ចប់ឆ្នាំសិក្សា ត្រូវមានការរៀបចំធ្វើតេស្តវាយតម្លៃ និងបូកសរុបលទ្ធផលដើម្បីដាក់សិស្សឱ្យត្រួតថ្នាក់ ឬ ឡើងថ្នាក់ (សូមមើលការណែនាំការវាយតម្លៃការសិក្សាចំណុចទី៧ខាងក្រោម)
- ការចាប់ផ្តើមឆ្នាំសិក្សា២០២០-២០២១ នឹងត្រូវអនុវត្តចាប់ពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ តទៅ។

## ៤- ការរៀបចំកាលវិភាគសិក្សា

- គ្រប់គ្រឹះស្ថានបឋមសិក្សាទាំងអស់ ត្រូវរៀបចំកាលវិភាគសិក្សាឡើងវិញ ចាប់ពីខែកញ្ញា ដល់ធ្នូ ឆ្នាំ ២០២០ ដោយផ្តោតលើមុខវិជ្ជាដូចបានកំណត់ក្នុងចំណុចទី៣ ខាងលើ
- ការរៀបចំកាលវិភាគសម្រាប់ការអនុវត្តពេញលេញ ថ្នាក់ទី១ ដល់ទី៦ (ទីរួមខេត្តទាំង ៤)៖ ថ្នាក់រៀននីមួយៗ ត្រូវរៀបចំសិស្សជាពីរក្រុម ដែលក្រុមទី១ ត្រូវរៀនជាមួយគ្រូផ្ទាល់រយៈពេល៣ថ្ងៃ/សប្តាហ៍ (ថ្ងៃចន្ទ ពុធ និងសុក្រ) និងរៀនខ្លួនឯងនៅផ្ទះ ឬតាមបណ្តុំ តាមរយៈការសិក្សាពីចម្ងាយនិងតាមប្រព័ន្ធអេឡិចត្រូនិក ៣ថ្ងៃ/សប្តាហ៍ (ថ្ងៃអង្គារ ព្រហស្បតិ៍ និងសៅរ៍) និងក្រុមទី២ ត្រូវរៀនឆ្លាស់ថ្ងៃគ្នាជាមួយក្រុមទី១
- ការរៀបចំកាលវិភាគសម្រាប់ការអនុវត្តទ្រង់ទ្រាយតូច ពីថ្នាក់ទី១ ដល់ទី៦ (ក្រៅពីរដ្ឋបាលក្រុងនៃខេត្តទាំង ៤ ខាងលើ) ថ្នាក់រៀននីមួយៗ ត្រូវរៀបចំសិស្សជា ៣ក្រុម ដែល៖
  ○ ក្រុមទី១ ត្រូវរៀនជាមួយគ្រូផ្ទាល់រយៈពេល ២ថ្ងៃ/សប្តាហ៍ (ថ្ងៃចន្ទ ព្រហស្បតិ៍) និងរៀនខ្លួនឯងនៅផ្ទះ ឬ តាមបណ្តុំ តាមរយៈការសិក្សាពីចម្ងាយនិងតាមប្រព័ន្ធអេឡិចត្រូនិក ៤ថ្ងៃ/សប្តាហ៍ (ថ្ងៃអង្គារ ពុធ សុក្រ និងសៅរ៍)
  ○ ក្រុមទី២ ត្រូវរៀនជាមួយគ្រូផ្ទាល់រយៈពេល ២ថ្ងៃ/សប្តាហ៍ (ថ្ងៃអង្គារ សុក្រ) និងរៀនខ្លួនឯងនៅផ្ទះ ឬ តាមបណ្តុំ តាមរយៈការសិក្សាពីចម្ងាយនិងតាមប្រព័ន្ធអេឡិចត្រូនិក ៤ថ្ងៃ/សប្តាហ៍ (ថ្ងៃចន្ទ ពុធ ព្រហស្បតិ៍ និងសៅរ៍)
  ○ ក្រុមទី៣ ត្រូវរៀនជាមួយគ្រូផ្ទាល់រយៈពេល ២ថ្ងៃ/សប្តាហ៍ (ថ្ងៃពុធ សៅរ៍) និងរៀនខ្លួនឯងនៅផ្ទះ ឬ តាមបណ្តុំ តាមរយៈការសិក្សាពីចម្ងាយនិងតាមប្រព័ន្ធអេឡិចត្រូនិក ៤ថ្ងៃ/សប្តាហ៍ (ថ្ងៃចន្ទ អង្គារ ព្រហស្បតិ៍ និងសុក្រ)។
- ការរៀបចំកាលវិភាគសិក្សាសម្រាប់សិស្សរៀនផ្ទាល់ជាមួយគ្រូនៅសាលារៀន ត្រូវបែងចែកម៉ោងសិក្សា ម៉ោងចូល ម៉ោងចេញលេង និងម៉ោងចេញទៅផ្ទះដែលមានលក្ខណៈឆ្លាស់ពេលគ្នា
- គ្រប់គ្រឹះស្ថានបឋមសិក្សា អាចមានភាពទន់ភ្លន់ក្នុងការរៀបចំកាលវិភាគទៅតាមភាពជាក់ស្តែង (ករណីខ្វះគ្រូ ខ្វះបន្ទប់រៀន...) នៃមូលដ្ឋានរបស់ខ្លួន
- ក្នុងមួយថ្នាក់មានចំណុះសិស្សចាប់ពី ១៥នាក់ ទៅ ២០នាក់។

6

**បញ្ជាក់៖** ចំពោះសាលាបឋមសិក្សាដែលត្រូវបានយកធ្វើជាមណ្ឌលចត្តាឡីស័ក គណៈកម្មការគ្រប់គ្រងសាលារៀន គណៈគ្រប់គ្រងសាលារៀន លោកគ្រូ អ្នកគ្រូ មាតាបិតា អ្នកអាណាព្យាបាល ត្រូវពិភាក្សាគ្នា ដើម្បីរៀបចំដំណើរការបង្រៀននិងរៀនទៅតាមលទ្ធភាព។ ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវដឹកនាំសម្របសម្រួលការងារនេះ ដោយរកទីតាំងសាលារៀនផ្សេងដែលនៅជិតបំផុត និងពិភាក្សាជាមួយសាមីសាលារៀនទាំងពីរ ដើម្បីបង្កលក្ខណៈឱ្យសិស្សបានរៀនស្មើគ្នាដូចៗគ្នា។

**៥- ការបង្កើតទម្លាប់អនាម័យថ្មីនៅតាមគ្រឹះស្ថានបឋមសិក្សា**

- ចូលរួមក្នុងការសម្អាតគ្រឹះស្ថានបឋមសិក្សាមុនពេលបើកដំណើរការឡើងវិញ និងអនុវត្តវិធានអនាម័យជាប្រចាំ ដោយប្រើប្រាស់សាប៊ូ អាល់កុល ឬ ជែលលាងដៃ និងត្រូវធានាការអនុវត្តតាមវិធានសុវត្ថិភាព ក្នុងការប្រើប្រាស់ និងការណែនាំប្រើប្រាស់ផលិតផលទាំងនោះ
- ណែនាំ ឬតម្រង់ទិសដល់អ្នកសិក្សា និងបុគ្គលិកអប់រំ អំពីវិធានអនាម័យ និងការយល់ដឹងអំពីរោគសញ្ញា និង ផលប៉ះពាល់នៃជំងឺកូវីដ-១៩
- រៀបចំកន្លែងលាងសម្អាតដៃ និងផ្តល់សាប៊ូលាងដៃ ។ល។ និងធានាថាមានទឹកស្អាតគ្រប់គ្រាន់សម្រាប់ការលាងសម្អាតដៃ
- សហការជាមួយមន្ត្រីសុខាភិបាល ដើម្បីវាស់សីតុណ្ហភាពរបស់អ្នកសិក្សា និងបុគ្គលិកអប់រំប្រចាំថ្ងៃ នៅច្រកចូលសាលារៀន ឬទីចាត់ការសាលារៀន
- បែងចែកថវិកា ឬកៀរគរថវិកាសម្រាប់ការទិញសាប៊ូលាងដៃ ទឹកអាល់កុល ឬជែលលាងដៃ ម៉ាស់ការពារ ស្រោមដៃ ។ល។
- រៀបចំឱ្យមានចំណតសមស្របនៅខាងក្រៅបរិវេណសាលារៀន ដើម្បីឱ្យមាតាបិតា ឬអ្នកអាណាព្យាបាលជូនកូនមករៀន និងមកទទួលកូនពីសាលារៀនវិញ
- មុនចូលបរិវេណសាលារៀន បុគ្គលិកអប់រំ សិស្សានុសិស្សត្រូវពាក់ម៉ាស់ ឬ របាំងមុខ និងបន្តពាក់ក្នុងអំឡុងពេលសិក្សា (សម្រាប់សិស្ស)
- នៅតាមក្លោងទ្វារ ឬ ច្រកចូលសាលារៀនត្រូវរៀបចំឱ្យមានការវាស់កម្តៅ អាល់កុល ឬជែលលាងដៃ និងម៉ាស់សម្រាប់សិស្សានុសិស្សដែលមិនមាន
- រៀបចំឱ្យមានការគោរពទង់ជាតិសម្រាប់តែបុគ្គលិកអប់រំ
- រៀបចំឱ្យមានគំនូសនៅតាមទីតាំងនៃការជួបជុំនានាក្នុងបរិវេណសាលារៀន ដើម្បីរក្សាបាននូវគម្លាតសង្គម
- កំណត់ចំនួនសិស្សានុសិស្សដែលប្រើប្រាស់បន្ទប់ទឹក ដោយមិនអនុញ្ញាតឱ្យចូលទាំងអស់គ្នានោះទេ
- មិនអនុញ្ញាតឱ្យមានការលក់ចំណីអាហារនៅក្នុងបរិវេណសាលារៀនឡើយ (មាតាបិតា ឬអ្នកអាណាព្យាបាលត្រូវរៀបចំអាហារ និងទឹកមកពីផ្ទះសម្រាប់កូនៗ)
- ជំរុញឱ្យមានការអប់រំសុខភាព អនុវត្តវិធីសាស្ត្រសុខភាពសិក្សា ផ្សព្វផ្សាយសារអប់រំសមស្របតាមអាយុនិងភាសា អំពីការលាងសម្អាតដៃ អនាម័យខ្លួនប្រាណ ការបង្ការជំងឺក្នុងសាលារៀន និងនៅក្នុងថ្នាក់រៀន
- ជំរុញនិងលើកទឹកចិត្តឱ្យបង្កើត **កម្មវិធីផលិតម៉ាស់នៅតាមសាលារៀន**

- ផ្ដល់ការគាំទ្រផ្នែកចិត្តសង្គមដល់អ្នកសិក្សានិងបុគ្គលិកអប់រំ ដើម្បីឱ្យពួកគេចេះទប់ទល់នឹងជំងឺបាក់ស្បាត ចេះគ្រប់គ្រងការថប់អារម្មណ៍ ដែលបង្កឡើងដោយជំងឺកូវីដ-១៩ ដូចជាការរស់នៅដាច់ដោយឡែក និងការរស់នៅក្នុងកន្លែងដែលមានរោគរាតត្បាត។ ប្រើប្រាស់ពាក្យពេចន៍ឬខ្លឹមសារគាំទ្រសុខភាពផ្លូវចិត្ត និងចិត្តសាស្ត្រ ដល់គ្រូបង្រៀន និងបុគ្គលិកសាលារៀន។ រៀបចំបញ្ជីផ្ទៀងផ្ទាត់សម្រាប់ការការពារ និងសុខុមាលភាពរបស់កុមារនៅក្នុងពេលបើកដំណើរការសាលារៀនឡើងវិញ
- ចំពោះបុគ្គលិក ឬសិស្សដែលមានប្រវត្តិធ្វើដំណើរត្រឡប់ពីបរទេស ឬបានប៉ះពាល់ផ្ទាល់ជាមួយបុគ្គលដែលត្រូវបានដាក់ឱ្យនៅដាច់ដោយឡែករយៈអំឡុងពេល ១៤ថ្ងៃ មិនត្រូវបានអនុញ្ញាតឱ្យចូលក្នុងបរិវេណសាលារៀនទេ ឬអាចអនុញ្ញាត លុះត្រាតែមានការបញ្ជាក់លទ្ធផលតេស្ត ពីមន្ទីរពេទ្យថាមិនមានជំងឺកូវីដ-១៩។ បុគ្គលិក ឬសិស្សមានជំងឺផ្ដាសាយធម្មតា ក៏មិនត្រូវបានអនុញ្ញាតឱ្យចូលក្នុងបរិវេណសាលារៀនដែរ។

## ៦- ការបង្រៀននិងរៀន

### ៦.១ មុនពេលបង្រៀន

- គណៈគ្រប់គ្រងសាលា និងគ្រូបង្រៀនត្រូវពិគ្រោះយោបល់ដើម្បីធ្វើវង្វាយតម្លៃការរៀនសូត្ររបស់សិស្សឆ្ពោះទៅកំណត់មេរៀន ដែលត្រូវចាប់ផ្ដើមបន្តបង្រៀន
- គ្រូបង្រៀនចាប់ផ្ដើមបង្រៀនខ្លឹមសារមេរៀនសម្រាប់ឆមាសទី២ និងអាចកំណត់ខ្លឹមសារមេរៀនដោយខ្លួនឯងអាស្រ័យលើសមត្ថភាពរបស់សិស្ស
- ខ្លឹមសារមេរៀននីមួយៗ ត្រូវមានលក្ខណៈសង្ខេបជាងការបង្រៀនធម្មតា ដោយផ្ដោតលើខ្លឹមសារសំខាន់ៗ ផ្អែកលើការអនុវត្តកិច្ចការផ្ទះរបស់សិស្សនៃសប្ដាហ៍នីមួយៗ។

### ៦.២ ដំណើរការបង្រៀន និងរៀន

គ្រប់គ្រឹះស្ថានបឋមសិក្សា ត្រូវអនុវត្តតាមរូបភាព ២ ដូចខាងក្រោម៖

- *រូបភាពទី១:* បន្តការសិក្សាតាមប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធផ្សព្វផ្សាយផ្លូវការ
  - ⇨ បន្តរៀបចំវីដេអូនៃការបង្រៀន ដោយរៀបចំសៀវភៅណែនាំគ្រូ តាមមុខវិជ្ជា និងតាមមេរៀន
  - ⇨ ជំរុញការរៀនពីចម្ងាយតាមប្រព័ន្ធផ្សព្វផ្សាយផ្លូវការ ដូចជា Facebook, YouTube, ទូរទស្សន៍។ល។
- *រូបភាពទី២:* អនុវត្តវិធីសាស្ត្រនៃការសិក្សាតាមបែបចម្រុះ (ការសិក្សាក្នុងថ្នាក់រៀន និងការសិក្សាពីចម្ងាយតាមបែបប្រពៃណី ឬ ការប្រើប្រាស់សន្លឹកកិច្ចការជំនួយ)។
  - ⇨ សាលារៀនត្រូវបង្កើតបន្ទប់សិក្សាអេឡិចត្រូនិក ដើម្បីផ្ទុកវីដេអូបង្រៀន និងឯកសារសន្លឹកកិច្ចការដទៃទៀត តាមរយៈការថតចម្លងដាក់ Hard Drive និងចែកជូនដល់សាលារៀន (នឹងមានការណែនាំដាច់ដោយឡែក)
  - ⇨ សាលារៀនដែលមានលទ្ធភាព ត្រូវរៀបចំការបង្រៀនតាមបែបបន្តផ្ទាល់ (LIVE) ពីក្នុងថ្នាក់រៀន
    - ជ្រើសរើសគ្រូបង្រៀនល្អ និងមានបទពិសោធ ដើម្បីបង្រៀនមេរៀនតាមកម្រិតថ្នាក់ រីឯគ្រូដទៃទៀតជួយសម្របសម្រួលការងារនានា ព្រមទាំងកែកិច្ចការសិស្ស
    - ត្រូវរៀបចំបញ្ជីរាយមុខមេរៀនតាមកម្រិតថ្នាក់ ដើម្បីចែកជូនគ្រូ សម្រាប់ជាជំនួយនៅក្នុងការសម្របសម្រួលលើការសិក្សារបស់សិស្សពីការផ្សាយបន្តផ្ទាល់នៃវីដេអូបង្រៀន

- អនុញ្ញាតឱ្យសិស្ស (ប្រមាណ ១៥ នាក់ទៅ ២០ នាក់ និងឆ្លាស់វេនគ្នា) ដើម្បីចូលរៀនជាមួយគ្រូ ដែលបង្រៀនតាមបែបបន្តផ្ទាល់ ដោយគោរពតាមគោលការណ៍ SOP និងផ្តល់អាទិភាពដល់សិស្សក្រីក្រនិងសិស្សគ្មានមធ្យោបាយសម្រាប់សិក្សាតាមបែបអេឡិចត្រូនិក

⇨ ចំពោះការសិក្សាតាមបែបប្រពៃណី នាយកដ្ឋានជំនាញ និង/ឬ គ្រូបង្រៀន នឹងរៀបចំការសង្ខេបមេរៀន និងសន្លឹកកិច្ចការជាជំនួយដល់ការសិក្សារបស់សិស្ស តាមមុខវិជ្ជា ដើម្បីចែករំលែកដល់សាលារៀន តាមរយៈមន្ទីរ អ.យ.ក.រាជធានី ខេត្ត និងការិយាល័យ អ.យ.ក. នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

## ៧. ការវាយតម្លៃការសិក្សារបស់សិស្ស

### ៧.១ មុនពេលដំណើរការរៀន

- រៀបចំការធ្វើតេស្តវាយតម្លៃការសិក្សារបស់សិស្សតាមកម្រិតថ្នាក់ និងតាមមុខវិជ្ជា (ដែលបានសិក្សាកន្លងមក) ដើម្បីឱ្យគ្រូបង្រៀនដឹងអំពីកម្រិតសមត្ថភាពរបស់សិស្សម្នាក់ៗ រួចរៀបចំនិងដឹកនាំការបង្រៀនទៅតាមកម្រិតសមត្ថភាពរបស់សិស្ស។

### ៧.២ ការវាយតម្លៃឡើងថ្នាក់

- រៀងរាល់សប្តាហ៍ទី៤ នៃខែនីមួយៗ (ខែកញ្ញា តុលា និងវិច្ឆិកា) គ្រូទទួលបន្ទុកថ្នាក់ត្រូវធ្វើតេស្តសិស្ស ដើម្បីដាក់ពិន្ទុប្រចាំខែ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យា
- ការប្រឡងឆមាសទី២ នឹងត្រូវធ្វើឡើង នៅសប្តាហ៍ទី២ នៃខែធ្នូ
- ការបូកសរុបលទ្ធផលប្រចាំឆមាសទី២ ត្រូវយកមធ្យមភាគនៃលទ្ធផលប្រឡងឆមាសទី២ បូកនិងមធ្យមភាគនៃលទ្ធផលប្រចាំខែឆមាសទី២ ហើយចែកនឹង២
- លទ្ធផលប្រចាំឆ្នាំសិក្សា ត្រូវយកមធ្យមភាគប្រចាំឆមាសទី១ បូកនឹងមធ្យមភាគប្រចាំឆមាសទី២ ចែកនឹង២
- សិស្សដែលទទួលបានលទ្ធផលមធ្យមភាគប្រចាំឆ្នាំចាប់ពី ៥.០០ ឡើងទៅ ត្រូវបានអនុញ្ញាតឱ្យឡើងថ្នាក់
- សិស្សដែលត្រួតថ្នាក់មួយឆ្នាំរួចហើយ ទោះបីធ្លាក់មធ្យមភាគ ក៏ត្រូវអនុញ្ញាតឱ្យឡើងថ្នាក់ដោយស្វ័យប្រវត្តិ
- សិស្សដែលទទួលបានលទ្ធផលមធ្យមភាគប្រចាំឆ្នាំក្រោម ៥.០០ ត្រូវបានអនុញ្ញាតឱ្យប្រឡងឡើងថ្នាក់ នៅដើមឆ្នាំសិក្សា២០២០-២០២១។ បើជាប់ត្រូវអនុញ្ញាតឱ្យឡើងថ្នាក់ ហើយបើធ្លាក់ត្រូវដាក់ឱ្យរៀនត្រួតថ្នាក់។

## ៨. ការគាំទ្រនិងអន្តរាគមន៍ផ្សេងៗ

- ផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈដល់គ្រូ ដូចជាផ្តល់ការរៀនសូត្រពីម្ខាយ តាមរយៈវីដេអូបង្រៀនដែលបានផ្សព្វផ្សាយនាពេលកន្លងមក
- គណៈគ្រប់គ្រងសាលារៀន លោកគ្រូអ្នកគ្រូ ត្រូវលើកទឹកចិត្តសិស្សឱ្យបានចូលរៀន និងចូលរួមរៀនសូត្រ តាមបំណែងចែកកម្មវិធីសិក្សា
- វាយតម្លៃលើផលប៉ះពាល់នៃការសិក្សា និងកំណត់ចំណុចខ្វះខាតដែលសិស្សជួបប្រទះក្នុងការរៀន

សូត្រ ដោយផ្ដោតការយកចិត្តទុកដាក់លើក្រុមកុមារងាយរងគ្រោះ

- អនុវត្តយុទ្ធសាស្ត្របំប៉ន និងអនុវត្តថ្នាក់ពន្លឿនការសិក្សាឱ្យបានសមស្រប ដោយធ្វើយ៉ាងណាឱ្យធានាបាននូវគុណភាព សមធម៌ និងបរិយាបន្ន
- បន្តលើកទឹកចិត្តសិស្សដែលងាយរងគ្រោះតាមរយៈការផ្ដល់ការគាំទ្រជាសម្ភារសិក្សា សម្លៀកបំពាក់ និងសម្ភារៈចាំបាច់ផ្សេងទៀត
- អនុញ្ញាតបន្តឱ្យសិស្សខ្ចីសៀវភៅសិក្សាគោល សៀវភៅរឿងខ្លីៗ និងឯកសារពាក់ព័ន្ធនឹងការរៀនសូត្រ ដើម្បីបានធ្វើស័យសិក្សានៅផ្ទះ
- ជ្រើសរើសគ្រូបង្រៀនស្ម័គ្រចិត្តដើម្បីជួយបង្រៀនសិស្សរៀនយឺតជាពិសេស តាមរយៈការបំប៉នបន្ថែម ឬ អនុវត្តកម្មវិធីពន្លឿនការសិក្សា
- បន្តគាំទ្រដល់សិស្សរៀនយឺត ផ្អែកតាមលទ្ធផលតេស្តវាយតម្លៃ និងរៀបចំក្រុមសិស្សរៀនយឺតសម្រាប់ការបង្រៀនបន្ថែម
- រៀបចំកាលវិភាគសិក្សា ដើម្បីធានាយ៉ាងណាឱ្យសិស្សរៀនយឺតអាចរៀនសូត្រពេញមួយសប្ដាហ៍
- រៀបចំការបង្រៀនបន្ថែម ការជួយបង្រៀនផ្ទាល់ សកម្មភាពរៀនសូត្រក្រៅប្រព័ន្ធ អប់រំបរិយាបន្ន អប់រំពហុភាសា និងអប់រំពិសេសបន្ថែមលើកម្មវិធីសិក្សាផ្លូវការ
- បន្តចែកសន្លឹកកិច្ចការឱ្យសិស្សយកទៅធ្វើនៅផ្ទះ និងយកចិត្តទុកដាក់លើការវាយតម្លៃការសិក្សារបស់សិស្ស ប្រមូល ត្រួតពិនិត្យ/កែកិច្ចការ និងផ្ដល់ព័ត៌មានត្រឡប់ដល់សិស្សជាប្រចាំ
- បន្តទំនាក់ទំនងល្អជាមួយមាតាបិតា អ្នកអាណាព្យាបាលសិស្ស ដោយផ្ដល់ព័ត៌មានអំពីការសិក្សារបស់កូនទៅពួកគាត់ជាប្រចាំ។

## ៩. ការចុះត្រួតពិនិត្យ អធិការកិច្ច និងរបាយការណ៍

### ៩.១ ករណីបុគ្គលិកសិក្សា គ្រូបង្រៀន ឬសិស្សានុសិស្សមានកម្ដៅខ្ពស់

- ករណីមានការពិនិត្យឃើញថា បុគ្គលិកសិក្សា គ្រូបង្រៀន ឬសិស្សានុសិស្សមានកម្ដៅលើសពី ៣៧,៥ អង្សាសេ អ្នកទាំងនោះមិនត្រូវអនុញ្ញាតឱ្យចូលក្នុងបរិវេណសាលា ឬបន្ទប់រៀននោះទេ ហើយត្រូវសហការជាមួយអាជ្ញាធរសុខាភិបាល ដើម្បីទៅរកសេវាព្យាបាលសមស្រប
- "**គណៈកម្មការគ្រប់គ្រងសាលារៀន**" ត្រូវជូនដំណឹងដល់មន្ទីរសុខាភិបាលជាបន្ទាន់ ឬតាមរយៈលេខទូរស័ព្ទទាន់ហេតុការណ៍ ១១៥ ក្នុងពេលមានការរកឃើញករណីសង្ស័យ មានជំងឺកូវីដ-១៩។

### ៩.២ ការរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន មណ្ឌលសុខភាព ដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល

- សហការជាមួយអាជ្ញាធររដ្ឋបាលមូលដ្ឋាន និងមណ្ឌលសុខភាព (ដែលនៅជិត) ដើម្បីកំណត់យន្តការតាមដាន ត្រួតពិនិត្យជាប្រចាំអំពីប្រជាជនចំណូលថ្មី និងចាត់វិធានការការពារ ទប់ស្កាត់ និងឆ្លើយតបចំពោះហានិភ័យនានាដែលអាចកើតមានឡើងជាយថាហេតុ ព្រមទាំងផ្ដល់ព័ត៌មានស្ដីពីស្ថានភាពសុខភាពរបស់ប្រជាជនទូទៅក្នុងរដ្ឋបាលមូលដ្ឋាន ជូនការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ

- ស្នើសុំមណ្ឌលសុខភាពឱ្យចាត់តាំងជនបង្គោលប្រចាំការ ដើម្បីងាយស្រួលទាក់ទងគ្នាចូលរួមអង្កេត និងអនុវត្តវិធានការការពារ ទប់ស្កាត់ និងឆ្លើយតបការរីករាលដាលជំងឺកូវីដ-១៩ និងរក្សាអនាម័យរបស់គ្រឹះស្ថានបឋមសិក្សា តាមការណែនាំរបស់ក្រសួងសុខាភិបាល
- សហការជាមួយដៃគូអភិវឌ្ឍ និងអង្គការសង្គមស៊ីវិល (ដូចជា ស.ស.យ.ក.) ដើម្បីស្វែងរកការជួយគាំទ្រផ្សេងៗ ដូចជា ការបង្រៀនបន្ថែម គ្រូស្ម័គ្រចិត្ត និងការគាំទ្រការសិក្សាពីចម្ងាយ ឬការចែកសន្លឹកកិច្ចការ សម្រាប់ដំណើរការបង្រៀន និងរៀនផ្ទាល់នៅតាមគ្រឹះស្ថានបឋមសិក្សា។

**៩.៣ ការធ្វើអធិការកិច្ច**

- ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចុះធ្វើអធិការកិច្ចជារួម
- មណ្ឌលសុខភាព ឬមន្ទីរពេទ្យបង្អែកដែលនៅជិតបំផុត ត្រូវចុះជួយជំរុញការអនុវត្តវិធានអនាម័យ និងគោលការណ៍ប្រតិបត្តិស្តង់ដា និងធ្វើអធិការកិច្ចសុខភាពសាធារណៈ នៅតាមគ្រឹះស្ថានបឋមសិក្សា
- ថ្នាក់ដឹកនាំក្រសួង នាយកដ្ឋានជំនាញ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវចុះពិនិត្យនិងអធិការកិច្ច ដើម្បីផ្តល់ការគាំទ្រនិងកែលម្អជាប្រចាំ នៅតាមគ្រឹះស្ថានបឋមសិក្សា។

**៩.៤ ការធ្វើរបាយការណ៍**

- **"គណៈគ្រប់គ្រងសាលារៀន"** ត្រូវរៀបចំ និងធ្វើរបាយការណ៍ប្រចាំខែ ស្តីពីដំណើរការរបស់គ្រឹះស្ថានសិក្សា ឱ្យបានទៀងទាត់តាមឋានានុក្រម។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងគ្រឹះស្ថានបឋមសិក្សា បុគ្គលិកអប់រំ អាជ្ញាធរដែនដី មាតាបិតាអ្នកអាណាព្យាបាលគ្រប់រូប សូមចូលរួមសហការអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ៧កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី **"ដើម្បីជ្រាបជាព័ត៌មាន"**
- គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត **"ដើម្បីអនុវត្ត"**
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានបឋមសិក្សា